**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ :** ៤៥ អនក្រ.បក

# អនុក្រឹត្យ

# ស្តីពី

# គុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៨២៣/១៩៨១ ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០២៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២២៤/២០៥ ចុះថ្ងៃទី២១ ខែកុម្ភៈ ឆ្នាំ២០២៤ ស្តីពីការតែងតាំងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៣២៣/០០១ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ២០២៣ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញអនុក្រឹត្យលេខ ៤៣ អនក្រ.បក ចុះថ្ងៃទី២៨ ខែកុម្ភៈ ឆ្នាំ២០២២ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៨៩ អនក្រ.បក ចុះថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០២៣ ស្តីពីការគ្រប់គ្រងថវិកានិងគណនេយ្យសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ១១៣ អនក្រ.បក ចុះថ្ងៃទី៦ ខែមិថុនា ឆ្នាំ២០២២ ស្តីពីការបង្កើតវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាគ្រឹះស្ថានសាធារណៈរដ្ឋបាល
- យោងតាមការស្នើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ កំណត់អំពីស្ថាប័នមានសមត្ថកិច្ច ប្រភេទមុខតំណែង លក្ខណវិនិច្ឆ័យគុណវុឌ្ឍិវិជ្ជាជីវៈ និងក្របខ័ណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ ដើម្បីពង្រឹងនិងអភិវឌ្ឍសមត្ថភាពមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈសំដៅចូលរួមចំណែកជានាប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**មាត្រា២.-**

អនុក្រឹត្យនេះ មានវិសាលភាពអនុវត្តចំពោះមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ ដែលមានភារកិច្ចអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

**មាត្រា៣.-**

និយមន័យនៃវាក្យសព្ទសំខាន់ៗដែលប្រើក្នុងអនុក្រឹត្យស្ដីពីគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈនេះ ត្រូវបានកំណត់ក្នុងសទ្ទានុក្រមដែលជាឧបសម្ព័ន្ធនៃអនុក្រឹត្យនេះ។

## ជំពូកទី២

## ស្ថាប័នមានសមត្ថកិច្ច

**មាត្រា៤.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានសមត្ថកិច្ចកសាង ពង្រឹង និងត្រួតពិនិត្យគុណវុឌ្ឍិវិជ្ជាជីវៈសម្រាប់ការតែងតាំងឬការប្រគល់ភារកិច្ចជូនមន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ ស្របតាមលិខិតបទដ្ឋានគតិយុត្តជាធរមាន។

វិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបំពេញមុខងារជាសេនាធិការជូនក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុលើការងារបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែងនិងការកសាងគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ។

**មាត្រា៥.-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល មានភារកិច្ចដូចខាងក្រោម៖

- ទទួលខុសត្រូវលើការចាត់បញ្ជូនមន្ត្រី ស្របតាមលក្ខណវិនិច្ឆ័យដែលមានចែងក្នុងមាត្រា៨និងមាត្រា៩ នៃអនុក្រឹត្យនេះដើម្បីចូលរួមកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង
- រៀបចំកញ្ចប់ថវិកាផែនការកសាងនិងអភិវឌ្ឍសមត្ថភាពលើជំនាញហិរញ្ញវត្ថុសាធារណៈប្រចាំឆ្នាំនីមួយៗ ដោយសហការជាមួយវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- ផ្តល់ពេលវេលាគ្រប់គ្រាន់និងរក្សាបៀវត្ស អតីតភាពការងារសម្រាប់ការឡើងថ្នាក់ ឋានន្តរសក្តិ មុខតំណែង និងការចូលនិវត្តន៍ ព្រមទាំងរក្សាមុខតំណែងក្នុងអង្គភាពដើម ចំពោះមន្ត្រីដែលបានចាត់បញ្ជូនចូលរួមកម្មវិធីបណ្តុះបណ្តាល
- សហការផ្តល់ព័ត៌មាននិងទិន្នន័យមន្ត្រី ដែលត្រូវចូលរួមកម្មវិធីបណ្តុះបណ្តាល និងត្រួតពិនិត្យលើប្រសិទ្ធភាពនៃការបំពេញការងារក្រោយទទួលបានការបណ្តុះបណ្តាល។

**មាត្រា៦.-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវតែងតាំងឬប្រគល់ភារកិច្ចអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ ជូនដល់មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈដែលមានគុណវុឌ្ឍិវិជ្ជាជីវៈ ស្របតាមការកំណត់ក្នុងមាត្រា៩ នៃអនុក្រឹត្យនេះ។

## ជំពូកទី៣
## ប្រភេទមុខតំណែងការងារនិងលក្ខណៈវិនិច្ឆ័យ
## នៃមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ

**មាត្រា៧.-**

ប្រភេទមុខតំណែងការងារមន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ មានដូចខាងក្រោម៖

- មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ
- មន្ត្រីនៃក្រុមការងារថវិកា
- រដ្ឋទេយ្យករបុរេប្រទាននិងរដ្ឋទេយ្យករបុរេប្រទានរង
- រដ្ឋទេយ្យករចំណូលនិងរដ្ឋទេយ្យករចំណូលរង
- មន្ត្រីនៃក្រុមលទ្ធកម្មនិងអង្គភាពលទ្ធកម្ម
- ភ្នាក់ងារបើកផ្តល់និងភ្នាក់ងារបើកផ្តល់ជំនួស
- មន្ត្រីគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ
- មន្ត្រីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ
- គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល
- គណនេយ្យករគណនីពិសេសរតនាគារ
- គណនេយ្យករថវិកាឧបសម្ព័ន្ធ
- មន្ត្រីគ្រប់គ្រងការងារគម្រោងវិនិយោគសាធារណៈ
- មន្ត្រីគ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន
- មន្ត្រីផ្សេងទៀតទទួលបន្ទុកការងារហិរញ្ញវត្ថុសាធារណៈដែលកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា៨.-**

មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈនិងមន្ត្រីពាក់ព័ន្ធ ដែលត្រូវចាត់ឱ្យចូលរួមកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង ត្រូវមានលក្ខណៈវិនិច្ឆ័យដូចខាងក្រោម៖

- ស្ថិតក្នុងមុខតំណែងឬត្រៀមទទួលមុខតំណែងពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុសាធារណៈ ដែលមិនទាន់មានគុណវុឌ្ឍិវិជ្ជាជីវៈតាមប្រភេទមុខតំណែងការងារនីមួយៗ
- មានលក្ខណសម្បត្តិល្អ ទទួលការវាយតម្លៃនិងការចាត់តាំងពីថ្នាក់ដឹកនាំអង្គភាព នៃក្រសួង ស្ថាប័នសាមី
- មានបទពិសោធឬចំណេះដឹងមូលដ្ឋានពាក់ព័ន្ធនឹង សេដ្ឋកិច្ច ហិរញ្ញវត្ថុ គណនេយ្យ ធនាគារ ការគ្រប់គ្រង ឬធុរកិច្ច រួមនឹងចំណេះដឹងចាំបាច់ក្នុងការប្រើប្រព័ន្ធបច្ចេកវិទ្យាព័ត៌មាន
- មានឆន្ទៈនិងស្មារតីទទួលខុសត្រូវខ្ពស់ ដើម្បីចូលរួមវគ្គសិក្សាតាមកម្មវិធីបណ្តុះបណ្តាលដែលបានកំណត់។

មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈនិងមន្ត្រីពាក់ព័ន្ធជាស្ត្រី ដែលមានលក្ខណវិនិច្ឆ័យដូចខាងលើ ត្រូវផ្តល់អាទិភាពឱ្យចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង។

## ជំពូកទី៤

## លក្ខខណ្ឌគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ

**មាត្រា៩.-**

ដើម្បីទទួលបានគុណវុឌ្ឍិវិជ្ជាជីវៈ មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈនិងមន្ត្រីពាក់ព័ន្ធ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានវិញ្ញាបនបត្រជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- មានអាកប្បកិរិយាថ្លៃថ្នូរ ឆន្ទៈ ស្មារតីវិជ្ជាជីវៈ ការទទួលខុសត្រូវខ្ពស់ និងឥរិយាបថបំពេញការងារជាក្រុម ដែលបញ្ជាក់ដោយអង្គភាពនៃក្រសួង ស្ថាប័នសាមី
- ត្រូវចូលរួមវគ្គវិក្រឹតការនិងសុក្រឹតការក្នុងរយៈពេល៣ឆ្នាំម្តងឬតាមការចាំបាច់ ដើម្បីធ្វើបច្ចុប្បន្នកម្មចំណេះដឹងជំនាញ ចំពោះមន្ត្រីមានគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ។

ការតែងតាំងមុខតំណែងឬការប្រគល់ភារកិច្ចការងារពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ ត្រូវអនុលោមតាមមាត្រា១៨ នៃអនុក្រឹត្យនេះ។

**មាត្រា១០.-**

ឧទ្ទេសាចារ្យដែលត្រូវចូលរួមបង្ហាត់បង្រៀន ក្នុងកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែងប្រចាំនៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបំពេញលក្ខខណ្ឌដូចខាងក្រោម៖

- មានកម្រិតសញ្ញាបត្រ ចាប់ពីបរិញ្ញាបត្រឡើងទៅលើជំនាញពាក់ព័ន្ធ
- មានបទពិសោធការងារយ៉ាងតិច៣ឆ្នាំក្នុងមុខងារពាក់ព័ន្ធមុខវិជ្ជាត្រូវបង្រៀន ឬមានវិញ្ញាបនបត្រកម្រិតទី៤ នៃកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង
- មានសមត្ថភាព ចំណេះដឹង ជំនាញឯកទេស និងទេពកោសល្យ លើមុខវិជ្ជាដែលត្រូវបង្រៀន
- មានសុខភាពល្អ អាកប្បកិរិយាថ្លៃថ្នូរ ឆន្ទៈ ស្មារតីវិជ្ជាជីវៈ និងការទទួលខុសត្រូវខ្ពស់

- ត្រូវចូលរួមវគ្គបណ្តុះបណ្តាលស្តីពីវិធីសាស្ត្របង្រៀន វគ្គរិក្រឹតការ ឬសុក្រឹតការលើមុខជំនាញពាក់ព័ន្ធ តាមការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៥
## ក្របខ័ណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ

**មាត្រា១១.-**

ក្របខ័ណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ មាន**៥កម្រិត** ដូចខាងក្រោម៖

- កម្រិតទី១ : សមត្ថភាពយល់ដឹងទូទៅ
- កម្រិតទី២ : សមត្ថភាពឯកទេសមូលដ្ឋាន
- កម្រិតទី៣ : សមត្ថភាពឯកទេសជំនាញ
- កម្រិតទី៤ : សមត្ថភាពឯកទេសជំនាញកម្រិតខ្ពស់
- កម្រិតទី៥ : សមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ក្របខ័ណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈ ត្រូវកសាងនិងអភិវឌ្ឍតាមរយៈកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង។

**មាត្រា១២.-**

សមត្ថភាពយល់ដឹងទូទៅ ត្រូវកសាងនិងអភិវឌ្ឍតាមរយៈកម្មវិធីបណ្តុះបណ្តាលឯកទេសតម្រង់ទិស ដែលជាកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតទី១ ដើម្បីលើកកម្ពស់ការយល់ដឹងនិងចំណេះដឹងអំពីគោលនយោបាយ យុទ្ធសាស្ត្រ គោលការណ៍ ច្បាប់ និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធនឹងការអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ។

កម្មវិធីបណ្តុះបណ្តាលនេះ តម្រូវចំពោះមន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈនិងមន្ត្រីពាក់ព័ន្ធ។

**មាត្រា១៣.-**

សមត្ថភាពឯកទេសមូលដ្ឋាន ត្រូវកសាងនិងអភិវឌ្ឍតាមរយៈកម្មវិធីបណ្តុះបណ្តាលឯកទេសមូលដ្ឋាន ដែលជាកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតទី២ ដើម្បីបង្កើនសមត្ថភាព ចំណេះដឹង ការយល់ដឹង និងទេពកោសល្យ លើឯកទេសមូលដ្ឋានពាក់ព័ន្ធនឹងការងាររដ្ឋទេយ្យ ការងារបើកផ្តល់ ការងាររៀបចំរបាយការណ៍ កិច្ចបញ្ជិកាគណនេយ្យ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ កិច្ចលទ្ធកម្មសាធារណៈ សវនកម្មផ្ទៃក្នុង និងការងារពាក់ព័ន្ធផ្សេងៗទៀត សម្រាប់អនុវត្តការងារហិរញ្ញវត្ថុសាធារណៈ។

កម្មវិធីបណ្តុះបណ្តាលនេះ តម្រូវចំពោះមន្ត្រីស្ថិតក្នុងមុខតំណែងឬត្រៀមទទួលមុខតំណែង ជារដ្ឋទេយ្យករបុរេប្រទានរង រដ្ឋទេយ្យករចំណូលរង ភ្នាក់ងារបើកផ្តល់ជំនួស ជំនួយការគណនេយ្យករ សមាជិកក្រុមការងារថវិកា សមាជិកគណៈកម្មការឬក្រុមការងារគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ សមាជិកគណៈកម្មាធិការលទ្ធកម្មឬសមាជិកក្រុមលទ្ធកម្ម សមាជិកគណៈកម្មការឬក្រុមការងារគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ ជំនួយការគម្រោងវិនិយោគសាធារណៈ សមាជិកគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ជំនួយការថ្នាក់ដឹកនាំទទួលការងារពាក់ព័ន្ធនឹងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមន្ត្រីជំនាញពាក់ព័ន្ធ ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលកម្រិតទី១។

**មាត្រា១៤.-**

សមត្ថភាពឯកទេសជំនាញ ត្រូវកសាងនិងអភិវឌ្ឍតាមរយៈកម្មវិធីបណ្តុះបណ្តាលឯកទេសជំនាញ ដែលជាកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតទី៣ ដើម្បីពង្រឹងពង្រីកសមត្ថភាព ចំណេះដឹងឯកទេស និងទេពកោសល្យ លើជំនាញឯកទេសពាក់ព័ន្ធនឹងការងារថវិកា ការងាររជ្ជទេយ្យ ការងារបើកផ្តល់ ការងាររៀបចំរបាយការណ៍ កិច្ចបញ្ជិកាគណនេយ្យ បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ កិច្ចលទ្ធកម្មសាធារណៈ សវនកម្មផ្ទៃក្នុង និងការងារពាក់ព័ន្ធផ្សេងៗទៀត សម្រាប់អនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

កម្មវិធីបណ្តុះបណ្តាលនេះ តម្រូវចំពោះមន្ត្រីស្ថិតក្នុងមុខតំណែងឬត្រៀមទទួលមុខតំណែង ជារជ្ជទេយ្យករ ភ្នាក់ងារបើកផ្តល់ គណនេយ្យករប្រចាំគ្រឹះស្ថានសាធារណៈរដ្ឋបាល មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ អនុប្រធានគណៈកម្មការឬក្រុមការងារគ្រប់គ្រងបញ្ជីសារពើភណ្ឌ អនុប្រធានគណៈកម្មការឬក្រុមការងារគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ អនុប្រធានអង្គភាពលទ្ធកម្ម អនុប្រធានក្រុមលទ្ធកម្ម អនុប្រធានក្រុមការងារថវិកា អនុប្រធានអង្គភាពសវនកម្មផ្ទៃក្នុង អនុប្រធានគម្រោងវិនិយោគសាធារណៈ និងអនុប្រធានគ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលកម្រិតទី២។

**មាត្រា១៥.-**

សមត្ថភាពឯកទេសជំនាញកម្រិតខ្ពស់ ត្រូវកសាងនិងអភិវឌ្ឍតាមរយៈកម្មវិធីបណ្តុះបណ្តាលឯកទេសជំនាញកម្រិតខ្ពស់ដែលជាកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតទី៤ ដើម្បីអភិវឌ្ឍសមត្ថភាពជំនាញ និងទេពកោសល្យវិជ្ជាជីវៈ លើជំនាញបច្ចេកទេសពាក់ព័ន្ធនឹងការគ្រប់គ្រងថវិកា លទ្ធកម្មសាធារណៈ គណនេយ្យសាធារណៈ សវនកម្មផ្ទៃក្នុង បញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ ការគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ ការគ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន និងការងារពាក់ព័ន្ធផ្សេងៗទៀត សម្រាប់អនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

កម្មវិធីបណ្តុះបណ្តាលនេះមានលក្ខណៈពិសេស តម្រូវចំពោះមន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ ដែលមានតួនាទីចាប់ពីអនុប្រធាននាយកដ្ឋាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងនាយកទីចាត់ការហិរញ្ញវត្ថុរាជធានី ខេត្ត សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬតួនាទីប្រហាក់ប្រហែលឡើងទៅ និងអតីតសិក្ខាកាមដែលបញ្ចប់វគ្គបណ្តុះបណ្តាលកម្រិតទី៣។

**មាត្រា១៦.-**

សមត្ថភាពគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវកសាងនិងអភិវឌ្ឍតាមរយៈកម្មវិធីបណ្តុះបណ្តាលគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលជាកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតទី៥ ដើម្បីពង្រឹងពង្រីកការយល់ដឹង និងអភិវឌ្ឍសមត្ថភាព លើជំនាញពាក់ព័ន្ធនឹងគោលនយោបាយ សេដ្ឋកិច្ច ហិរញ្ញវត្ថុសាធារណៈ និងភាពជាអ្នកដឹកនាំនិងការគ្រប់គ្រងការផ្លាស់ប្តូរ ជាដើម សំដៅធានាប្រសិទ្ធភាពនៃការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយនិងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

កម្មវិធីបណ្តុះបណ្តាលនេះមានលក្ខណៈពិសេស តម្រូវចំពោះថ្នាក់ដឹកនាំដែលមានតួនាទីចាប់ពីអគ្គនាយករង សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងអភិបាលរងរាជធានី ខេត្ត សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬតួនាទីប្រហាក់ប្រហែលឡើងទៅ និងអតីតសិក្ខាកាមដែលបញ្ចប់វគ្គបណ្តុះបណ្តាលកម្រិតទី៤។

**មាត្រា១៧.-**

មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈនិងមន្ត្រីពាក់ព័ន្ធ ដែលបានបញ្ចប់វគ្គបណ្តុះបណ្តាលកម្រិតទី១ដោយជោគជ័យ អាចបន្តចូលរួមវគ្គបណ្តុះបណ្តាលកម្រិតទី២និងកម្រិតបន្តបន្ទាប់។

**មាត្រា១៨.-**

ក្របខ័ណ្ឌសមត្ថភាពជំនាញហិរញ្ញវត្ថុសាធារណៈកម្រិតទី២ កម្រិតទី៣ និងកម្រិតទី៤ គឺជាមូលដ្ឋាន សម្រាប់ការតែងតាំងមុខតំណែងឬការប្រគល់ភារកិច្ចការងារពាក់ព័ន្ធនឹងហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ ព្រមទាំងច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា១៩.-**

ការបណ្តុះបណ្តាលកម្រិតទី១ កម្រិតទី២ និងកម្រិតទី៣ ដូចមានកំណត់ក្នុងមាត្រា១២ មាត្រា១៣ និងមាត្រា១៤ខាងលើ ពុំមែនជាកាតព្វកិច្ច ចំពោះមន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ ដែលមានតួនាទីចាប់ពីអនុប្រធាននាយកដ្ឋាន សម្រាប់រដ្ឋបាលថ្នាក់ជាតិ និងនាយកទីចាត់ការហិរញ្ញវត្ថុ រាជធានី ខេត្ត សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ឬតួនាទីប្រហាក់ប្រហែលឡើងទៅ។

## ជំពូកទី៦
## បន្ទុកចំណាយនិងថ្លៃសេវា

**មាត្រា២០.-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ត្រូវរ៉ាប់រងការចំណាយនិងការបង់ថ្លៃចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង សម្រាប់មន្ត្រីរបស់ខ្លួន។

**មាត្រា២១.-**

ថ្លៃសេវាបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ជំពូកទី៧
## ការលើកទឹកចិត្តនិងទណ្ឌកម្ម
### ផ្នែកទី១
### ការលើកទឹកចិត្ត

**មាត្រា២២.-**

ក្រោយបញ្ចប់ការបណ្តុះបណ្តាលដោយជោគជ័យ សិក្ខាកាមទទួលបាន៖

- វិញ្ញាបនបត្របញ្ជាក់ការសិក្សា ចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ ជាមូលដ្ឋាននៃការតែងតាំងមុខតំណែងឬការប្រគល់ភារកិច្ចពាក់ព័ន្ធនឹងការងារហិរញ្ញវត្ថុសាធារណៈ តាមកម្រិតសមត្ថភាពនីមួយៗ

- អាទិភាពក្នុងការវាយតម្លៃសម្រាប់ដំឡើងថ្នាក់តាមវេនប្រចាំឆ្នាំ ក្រោយបញ្ចប់ការបណ្ដុះបណ្ដាល ដោយជោគជ័យនៅកម្រិតទី៤ នៃជំនាញនីមួយៗចំពោះសិក្ខាកាមជាមន្ត្រីរាជការ
- អាទិភាពក្នុងការជ្រើសរើសជាគ្រូបង្គោល ក្រោយបញ្ចប់ការបណ្ដុះបណ្ដាលដោយជោគជ័យ នៅកម្រិតទី៤ នៃជំនាញនីមួយៗ។

**មាត្រា២៣.-**

ឧទ្ទេសាចារ្យដែលមានស្នាដៃល្អក្នុងការបង្ហាត់បង្រៀន ទទួលបាន៖

- ការផ្ដល់ឋានៈឧទ្ទេសាចារ្យ ប្រចាំនៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- គ្រឿងឥស្សរិយយសឬបណ្ណសរសើរ
- ឱកាសចូលរួមទស្សនកិច្ចសិក្សា សិក្ខាសាលា សន្និសីទ និងកម្មវិធីបណ្ដុះបណ្ដាលក្រៅប្រទេស
- ការលើកទឹកចិត្តនិងអត្ថប្រយោជន៍ផ្សេងទៀត តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ។

គោលការណ៍ ប្រភេទ និងនីតិវិធីនៃការផ្ដល់ឋានៈឧទ្ទេសាចារ្យ ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៤.-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលបានចាត់បញ្ជូនមន្ត្រីចូលរួមវគ្គបណ្ដុះបណ្ដាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង ទទួលបាន៖

- ការគាំទ្រជាអាទិភាពលើការកសាងនិងអភិវឌ្ឍសមត្ថភាពជំនាញគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ការលើកទឹកចិត្តផ្សេងទៀត តាមការសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

## ផ្នែកទី២

## ទណ្ឌកម្ម

**មាត្រា២៥.-**

ក្រោយរយៈពេល៣ឆ្នាំបន្ទាប់ពីអនុក្រឹត្យនេះចូលជាធរមាន មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ ដែលគ្មានវិញ្ញាបនបត្រពីកម្មវិធីបណ្ដុះបណ្ដាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង ត្រូវផ្លាស់ប្ដូរឬជំនួសដោយមន្ត្រីមានគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈតាមប្រភេទមុខតំណែងការងារនីមួយៗ ដោយអនុលោមតាមច្បាប់និងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធជាធរមាន។

**មាត្រា២៦.-**

មន្ត្រីដែលត្រូវបានចាត់ឱ្យចូលរួមវគ្គបណ្ដុះបណ្ដាល និងមិនបានបំពេញតាមលក្ខខណ្ឌកំណត់នៃកម្មវិធីបណ្ដុះបណ្ដាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង ត្រូវជាកម្មវត្ថុដូចខាងក្រោម៖

- មិនអនុញ្ញាតឱ្យប្រឡងបញ្ចប់ការសិក្សា
- មិនមានសិទ្ធិទទួលវិញ្ញាបនបត្របញ្ជាក់ការសិក្សា
- មិនទទួលបានគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ

- មិនទទួលបានការតែងតាំងមុខតំណែងឬការប្រគល់ភារកិច្ចពាក់ព័ន្ធការងារហិរញ្ញវត្ថុសាធារណៈ
- មិនអនុញ្ញាតឱ្យបន្តចូលរួមកម្មវិធីបណ្តុះបណ្តាលរបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៧.-**

ឧទ្ទេសាចារ្យដែលមិនបានអនុវត្តតាមលក្ខខណ្ឌកំណត់ក្នុងកម្មវិធីបណ្តុះបណ្តាល ត្រូវទទួលទណ្ឌកម្មដូចខាងក្រោម៖

- ផ្អាកការបង្រៀនរហូតដល់មានការកែលម្អតាមលក្ខខណ្ឌកំណត់ក្នុងកម្មវិធីបណ្តុះបណ្តាល
- ជូនដំណឹងឬផ្តល់ការណែនាំជាលាយលក្ខណ៍អក្សរ
- បាត់បង់ឱកាសទទួលបានឋានៈឧទ្ទេសាចារ្យ ប្រចាំនៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**មាត្រា២៨.-**

ក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល ដែលមិនអនុវត្តតាមអនុក្រឹត្យនេះ ជាកម្មវត្ថុនៃការមិនទទួលបានការគាំទ្រលើការស្នើតែងតាំង ឬការប្រគល់ភារកិច្ចដល់មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ។

## ជំពូកទី៨
## ការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃ

**មាត្រា២៩.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ ត្រូវតាមដានត្រួតពិនិត្យ និងវាយតម្លៃតម្រូវការ គុណភាព និងប្រសិទ្ធភាពនៃកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង។

**មាត្រា៣០.-**

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុជាសេនាធិការ ត្រូវផ្ទៀងផ្ទាត់អនុលោមភាពលើការតែងតាំងឬការផ្លាស់ប្តូរមុខតំណែង និងការប្រគល់ភារកិច្ចជូនមន្ត្រីដែលមានគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ សម្រាប់អនុវត្តការងារហិរញ្ញវត្ថុសាធារណៈ នៅតាមក្រសួង ស្ថាប័ន អង្គភាពសាធារណៈប្រហាក់ប្រហែល រដ្ឋបាលថ្នាក់ក្រោមជាតិ និងគ្រឹះស្ថានសាធារណៈរដ្ឋបាល។

## ជំពូកទី៩
## អន្តរប្បញ្ញត្តិ

**មាត្រា៣១.-**

វិញ្ញាបនបត្របញ្ជាក់ការសិក្សាពីកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសលើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈដែលបានចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មុនអនុក្រឹត្យនេះចូលជាធរមាន ត្រូវសមមូលនឹងវិញ្ញាបនបត្រកម្រិតទី២នៃកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង ដូចមានចែងក្នុងមាត្រា១៣ នៃអនុក្រឹត្យនេះ។

ក្រោយអនុក្រឹត្យនេះចូលជាធរមាន មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈដែលមិនមានគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ ស្របតាមប្រភេទមុខតំណែងការងារនីមួយៗ ត្រូវចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង។

## ជំពូកទី១០

## អវសានប្បញ្ញត្តិ

**មាត្រា៣២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន និងអង្គភាពសាធារណៈប្រហាក់ប្រហែលដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ចន្ទ២ កើត ខែ ផល្គុន ឆ្នាំថោះ បញ្ចស័ក ព.ស.២៥៦៧

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២៤

**នាយករដ្ឋមន្ត្រី**

**សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត**

បានយកសេចក្តីគោរពជម្រាបជូន

សម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**ឧបនាយករដ្ឋមន្ត្រី**

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គបណ្ឌិតសភាចារ្យ **អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល៖**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- ខុទ្ទកាល័យសម្តេចមហាបវរធិបតីនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៣២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

## ឧបសម្ព័ន្ធនៃអនុក្រឹត្យលេខ ៤៥ អនក្រ.បក ចុះថ្ងៃទី ១១ ខែ មីនា ឆ្នាំ២០២៤
## ស្តីពីគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ
## សទ្ទានុក្រម

វាក្យសព្ទដែលបានប្រើក្នុងអនុក្រឹត្យស្តីពីគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ ត្រូវបានកំណត់និយមន័យដូចតទៅ៖

**ក្របខ័ណ្ឌសមត្ថភាព** សំដៅដល់កម្រិតសមត្ថភាពដែលត្រូវបានកំណត់តាមជំនាញនិងប្រភេទមុខតំណែងរបស់មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ។

**ការកសាងគុណវុឌ្ឍិវិជ្ជាជីវៈ** សំដៅដល់ដំណើរការរៀបចំ និង អនុវត្តកម្មវិធីបណ្តុះបណ្តាលសម្រាប់បំពាក់គុណវុឌ្ឍិវិជ្ជាជីវៈផ្សារភ្ជាប់មុខតំណែង តាមរយៈវិញ្ញាបនបត្របញ្ជាក់លទ្ធផលសិក្សា ដើម្បីអនុវត្តតួនាទី ភារកិច្ចប្រកបដោយវិជ្ជាជីវៈឆ្លើយតបទៅនឹងស្តង់ដាប្រតិបត្តិ និងធានាប្រសិទ្ធភាពការងារ។

**គណនេយ្យករថវិកាឧបសម្ព័ន្ធ** សំដៅដល់ភ្នាក់ងាររបស់រដ្ឋដែលទទួលបន្ទុកលើកិច្ចការទទួលនិងគ្រប់គ្រងចំណូល ទូទាត់ចំណាយ រក្សាទុកដាក់និងគ្រប់គ្រងសាច់ប្រាក់ កាន់បញ្ជីគណនេយ្យ និងរៀបចំរបាយការណ៍ថវិកានិងហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងការអនុវត្តថវិកាឧបសម្ព័ន្ធទាំងនៅថ្នាក់ជាតិ និងនៅរដ្ឋបាលថ្នាក់ក្រោមជាតិ។ គណនេយ្យករថវិកាឧបសម្ព័ន្ធ ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ។

**គុណវុឌ្ឍិវិជ្ជាជីវៈ** សំដៅដល់បណ្តុំសមត្ថភាព ជំនាញវិជ្ជាជីវៈ និងទេពកោសល្យ ដែលឆ្លើយតបទៅនឹងមុខតំណែង តួនាទី និងភារកិច្ចសំខាន់ៗនៅតាមអង្គភាពការងារ។

**គុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈ** សំដៅដល់គុណវុឌ្ឍិវិជ្ជាជីវៈ ដែលទទួលបានតាមរយៈការបណ្តុះបណ្តាលជំនាញហិរញ្ញវត្ថុសាធារណៈ ពីកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង។

**គណនេយ្យករគណនីពិសេសរតនាគារ** សំដៅដល់ភ្នាក់ងាររបស់រដ្ឋដែលទទួលបន្ទុកលើកិច្ចការទទួលនិងគ្រប់គ្រងចំណូល ទូទាត់ចំណាយ រក្សាទុកដាក់និងគ្រប់គ្រងសាច់ប្រាក់ កាន់បញ្ជីគណនេយ្យ និងរៀបចំរបាយការណ៍ថវិកានិងហិរញ្ញវត្ថុ ដែលពាក់ព័ន្ធនឹងការអនុវត្តគណនីពិសេសរតនាគារ។ គណនេយ្យករគណនីពិសេសរតនាគារ ត្រូវបានតែងតាំងដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមរយៈអគ្គនាយកដ្ឋានរតនាគារជាតិ។

**ឧទ្ទេសាចារ្យ** សំដៅដល់មន្ត្រីរាជការឬមន្ត្រីចូលនិវត្តន៍ ឬក៏អ្នកជំនាញ ដែលមានលក្ខណសម្បត្តិគ្រប់គ្រាន់ ដូចការកំណត់ក្នុងមាត្រា១០ នៃអនុក្រឹត្យនេះ និងមានមុខងាររៀបចំកម្មវិធី ឯកសារមេរៀន និងជាអ្នកបង្ហាត់បង្រៀន ប្រចាំនៅវិទ្យាស្ថានសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ភ្នាក់ងារបើកផ្តល់** សំដៅដល់អ្នកបើកបៀវត្សនិងលាភការផ្សេងៗរបស់បុគ្គលិកនិងមន្ត្រីរាជការ។

**មន្ត្រីរាជការជំនាញហិរញ្ញវត្ថុសាធារណៈ** សំដៅដល់មន្ត្រីរាជការដែលមានភារកិច្ចអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ និងដែលមានគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈតាមប្រភេទមុខតំណែងការងារនីមួយៗ។

**មន្ត្រីអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ** សំដៅដល់មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីលក្ខន្តិកៈ ឬបុគ្គលិកជាប់កិច្ចសន្យា ដែលមានភារកិច្ចអនុវត្តការងារហិរញ្ញវត្ថុសាធារណៈ ប៉ុន្តែមិនទាន់ទទួលគុណវុឌ្ឍិវិជ្ជាជីវៈជំនាញហិរញ្ញវត្ថុសាធារណៈតាមប្រភេទមុខតំណែងការងារនីមួយៗ។

**មន្ត្រីមានគុណវុឌ្ឍិវិជ្ជាជីវៈហិរញ្ញវត្ថុសាធារណៈ** សំដៅដល់មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីលក្ខន្តិកៈ ឬបុគ្គលិកជាប់កិច្ចសន្យា ដែលបានទទួលការបណ្តុះបណ្តាលជំនាញហិរញ្ញវត្ថុសាធារណៈ ពីកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង។

**មន្ត្រីពាក់ព័ន្ធ** សំដៅដល់មន្ត្រីរាជការ មន្ត្រីជាប់កិច្ចសន្យា មន្ត្រីលក្ខន្តិកៈ ឬបុគ្គលិកជាប់កិច្ចសន្យាដែលមានតម្រូវការបណ្តុះបណ្តាលជំនាញហិរញ្ញវត្ថុសាធារណៈពីកម្មវិធីបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង។

**មន្ត្រីគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋ** សំដៅដល់មន្ត្រីដែលទទួលបន្ទុកអនុវត្តការងារគ្រប់គ្រងបញ្ជីសារពើភណ្ឌទ្រព្យសម្បត្តិរដ្ឋរបស់អង្គភាពថវិកា។

**មន្ត្រីគ្រប់គ្រងចំណូលមិនមែនសារពើពន្ធ** សំដៅដល់មន្ត្រីដែលទទួលបន្ទុកអនុវត្តការងារគ្រប់គ្រងចំណូលមិនមែនសារពើពន្ធរបស់អង្គភាពថវិកា។

**មន្ត្រីគ្រប់គ្រងការងារគម្រោងវិនិយោគសាធារណៈ** សំដៅដល់មន្ត្រីដែលទទួលបន្ទុកអនុវត្តការងារគ្រប់គ្រងគម្រោងវិនិយោគសាធារណៈ។

**មន្ត្រីគ្រប់គ្រងការងារគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន** សំដៅដល់មន្ត្រីដែលទទួលបន្ទុកអនុវត្តការងារគ្រប់គ្រងគម្រោងភាពជាដៃគូរវាងរដ្ឋនិងឯកជន។

**មន្ត្រីគ្រប់គ្រងហិរញ្ញវត្ថុ** សំដៅដល់មន្ត្រីជាសេនាធិការរបស់ប្រធានអង្គភាពថវិកា ដែលត្រូវអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុ ដោយត្រូវគោរពតាមវិធាននិងបទប្បញ្ញត្តិហិរញ្ញវត្ថុជាធរមាន។

**មន្ត្រីនៃក្រុមលទ្ធកម្ម** សំដៅដល់មន្ត្រីដែលមានភារកិច្ចជាប្រធាន អនុប្រធាន ឬសមាជិកនៃក្រុមលទ្ធកម្ម។

**មន្ត្រីនៃអង្គភាពលទ្ធកម្ម** សំដៅដល់មន្ត្រីដែលមានភារកិច្ចជាប្រធាន អនុប្រធាន ឬសមាជិកនៃអង្គភាពលទ្ធកម្ម។

**មន្ត្រីនៃក្រុមការងារថវិកា** សំដៅដល់មន្ត្រីដែលមានភារកិច្ចជាប្រធាន អនុប្រធាន ឬសមាជិកនៃក្រុមការងារថវិកា។

**រដ្ឋលេខាធិការចំណូល** សំដៅដល់មន្ត្រីកត់ត្រា ចុះបញ្ជី និងប្រមូលប្រាក់ចំណូលទាំងអស់បង់ចូលថវិការដ្ឋ។

**រដ្ឋលេខាធិការបុរេប្រទាន** សំដៅដល់មន្ត្រីបើកប្រាក់រដ្ឋលេខាធិការបុរេប្រទាន និងធ្វើប្រតិបត្តិការទូទាត់ចំណាយវិញ យ៉ាងយូរបំផុតក្នុងរយៈពេល១ខែ ចាប់ពីកាលបរិច្ឆេទបើកប្រាក់។

**វគ្គវិក្រឹតការ** សំដៅដល់ប្រភេទវគ្គបណ្តុះបណ្តាលដែលត្រូវបានរៀបចំបំពេញបន្ថែមជូនដល់សិក្ខាកាមលើជំនាញ ចំណេះដឹង និងឥរិយាបថការងារ ដើម្បីអនុវត្តការងារឱ្យកាន់តែមានប្រសិទ្ធភាព។

**វគ្គសុក្រឹតការ** សំដៅដល់ប្រភេទវគ្គបណ្តុះបណ្តាលដែលត្រូវបានរៀបចំឡើង ដើម្បីធ្វើបច្ចុប្បន្នកម្មលើជំនាញ ចំណេះដឹង និងឥរិយាបថការងារ ស្របតាមបរិបទការងារជាក់ស្តែង។

**វិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង** សំដៅដល់វិញ្ញាបនបត្រដែលចេញដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជូនដល់សិក្ខាកាមដែលបានចូលរួមវគ្គបណ្តុះបណ្តាលជំនាញបច្ចេកទេសកម្រិតវិញ្ញាបនបត្រផ្សារភ្ជាប់មុខតំណែង កម្រិតទី២ កម្រិតទី៣ ឬកម្រិតទី៤ ដោយជោគជ័យ។